# ១២.រឿង សុភាទន្សាយ

## ពាក្យរាយតពីពាក្យកាព្យ

ដំណាលពីរឿងទន្សាយ កាលដែលរត់ពីអណ្ដូងទៅនោះ ទៅឈប់ជិតភូមិមួយ មានយាយចាស់ម្នាក់ទូលចេកទៅលក់ ទន្សាយនោះឃើញ គិតថា «ឥឡូវអញអស់កម្លាំងម្ល៉េះ ធ្វើម្ដេចនឹងបានចេកនោះស៊ី មានតែធ្វើជាស្លាប់» គិតហើយលូនទៅដេកនៅផ្លូវ ។ ឯយាយចាស់នោះទូលចេកដើរមកដល់ ឃើញទន្សាយគិតស្មានថាជាស្លាប់មែន ហើយលាន់មាត់ថា «អះអញមកលក់ចេកថ្ងៃនេះ ហៅពេញជាមានលាភសុន្ទរពន់ពេកណាស់ អញនឹងយកអាទន្សាយនេះទៅស្លស៊ីបានម្ដង» ហើយក៏លើកទន្សាយនោះដាក់ក្នុងល្អីដើរទៅ ។ ឯទន្សាយកាលបើយាយចាស់ដាក់ទៅលើល្អីចេកហើយ ក៏បកស៊ី ៗ ។ លុះយាយចាស់នោះដល់ទៅផ្ទះគេ ៗ ហៅទិញចេក គាត់ដាក់កញ្ជើចេកពីលើក្បាលមក ទន្សាយវាលោតបោលទៅ មើលទៅចេកនៅសល់តែសំបក ។ យាយចាស់នោះថា «ម៉ែ អាទន្សាយនេះវារស់ទេតើ អញស្មានថាវាងាប់» ។ ចេកនោះ ក៏អស់ខានលក់, ទន្សាយនោះក៏វាបោលរួចទៅ ។

ឯទន្សាយ កាលបោលពីភូមិនោះចូលទៅក្នុងព្រៃ ចុះទៅក្នុងត្រពាំងមួយប្រុងនឹងផឹកទឹក ។ កាលនោះ មានខ្យងក្នុងត្រពាំងនោះវាឃាត់ថា «អាទន្សាយឯងម្ដេចក៏មកផឹកទឹកអញ» ។ ទន្សាយឆ្លើយថា « ថ្វី! បើអញផឹកទឹកផង, ទឹកម៉ែឪអាណា? » ។ ខ្យងថា « អើទឹកផងអញ!» ។ ទន្សាយឆ្លើយថា « បើច្នោះឯងបោលភ្នាល់នឹងអញ អញបោលលើគោក ឯងហែលក្នុងទឹក បើឯងហែលលឿនជាងអញ ៗ ខានផឹកទឹកត្រពាំងនេះ បើអញបោលលឿនជាងឯង អញផឹកទឹកត្រពាំងនេះ» ។ ខ្យងក៏ព្រមភ្នាល់ ទើបខ្យងវាគិតគ្នាវាថា «យើងបណ្ដាក់គ្នា ឲ្យជុំវិញមាត់ត្រពាំងនេះ បើទន្សាយវាស្រែកហៅ កុំឲ្យអ្នកឯក្រោយឆ្លើយឡើយ ឲ្យអ្នកណាដែលនៅឯមុខនោះឆ្លើយឡើង» ។ គិតគ្នារួចស្រេចហើយស្រែកប្រាប់ទៅទន្សាយថា «ទន្សាយពោលទៅចុះ!» ។ ទន្សាយបោលទៅៗ ស្រែកហៅទៅខ្យង ៗ ឯមុខឆ្លើយថា «កូ៎ក !» ។ ទន្សាយថា «ម៉ែ! អានេះហែលលឿនទៅឆ្ងាយណាស់» ។ ទន្សាយបោលទៅទៀត ហើយហៅទៀត ខ្យងមុខនោះឆ្លើយឡើងទៀត បោលពុំចេះទាន់ឡើយ ។ ទន្សាយទទួលចាញ់ប្រាជ្ញាខ្យង ពុំហ៊ានផឹកទឹកត្រពាំងបឹងបួឯណាឡើយ ផឹកតែទឹកសន្សើមតាំងពីនោះមក ។

ឯទន្សាយបោលពីនោះទៅទៀត គិតនឹងឆ្លងត្រើយម្ខាង ពុំដឹងគិតធ្វើដូចម្ដេចនឹងឆ្លងទៅបាន ។ កាលនោះ មានក្រពើមួយហែលចុះហែលឡើង ។ ទន្សាយឃើញហើយគិតថា «អញធ្វើដូចម្ដេច នឹងបានអាក្រពើនេះចម្លងអញទៅដាក់ត្រើយនាយ? » គិតហើយធ្វើជាសួរថា «បងក្រពើ! បងឯងកើតអ្វីបានជាគគ្រាតអស់ទាំងខ្លួន? » ។ ក្រពើនោះប្រាប់ទៅវិញថា «គេហៅកើតស្រែង» ។ ទន្សាយថា «បងឯងចម្លងអញឲ្យតែដល់ត្រើយនាយចុះ អញនឹងមើលស្រែងបងឯងឲ្យជា» ។ ឯក្រពើឮគេថានឹងមើលស្រែងឲ្យជាដូច្នោះ ក៏អរណាស់ឡើងមកបង្អើលខ្លួនលើគោក ហើយថា «អញចម្លងអ្នកឯងទៅ, អ្នកឯងមើលស្រែងអញឲ្យជាចុះ ។ ទន្សាយថា «អើ! កុំភ័យ» ។ ទន្សាយវាខ្ចើមខ្លួនក្រពើ វាកាច់ស្លឹកឈើទ្រាប់អង្គុយ ។ ក្រពើសួរថា «ចាំទ្រាប់ស្លឹកឈើធ្វើអ្វី??» ។ ទន្សាយថា «បងឯងមានគុណនឹងខ្ញុំក្រែងវាបាបខ្ញុំ» ។ ហើយទន្សាយឡើងជិះលើក្បាលក្រពើនោះ ។ ឯក្រពើជឿស្មោះ ចំពោះថាជាត្រង់ពិតមែន ខំហែលចម្លងបានដល់ទៅត្រើយនាយ ។ ទន្សាយចុះពីលើក្បាលក្រពើ បោលឡើងទៅលើគោក ហើយស្រែកថា «ស្រែងអាឯង កើតតាំងពីជីដូនជីតាអាឯងមកអាណាមើលជា» ។ ក្រពើខឹងណាស់ គិតថា «អាទន្សាយនេះ វាបញ្ឆោតអញដល់ខ្ទាត

ហើយ ពុំដឹងធ្វើដូចម្ដេចនឹងខាំវាបាន» គិតហើយធ្វើដូចគល់អណ្ដែតទឹករសាត់ចុះឡើង ។ ទន្សាយនោះ វាបោលទៅបោលមក ឃើញឯក្របីមួយងាប់នៅមាត់ត្រពាំង ត្មាតវារូងពោះក្របីនោះ ទន្សាយវាក៏ទៅចូលលេង, ដល់ត្រូវថ្ងៃក្ដៅគូទក្របីនោះវាខ្ទឹបជិត ទន្សាយចេញវិញពុំរួច វិលវល់នៅក្នុងពោះក្របីនោះ ទាល់តែល្ងាច ។ លុះល្ងាច មានមនុស្សមកដងទឹក ទន្សាយថា «ឱអស់អ្នកស្រុកអាណិតដងទឹកមកស្រោចគូទក្របីនេះឲ្យទានផង មេត្តាប្រោសយកតែបុណ្យទៅចុះ លោកបានបុណ្យច្រើនណាស់ ។ អ្នកដងទឹកគេឮច្រើនដង ក៏ដងទឹកទៅស្រោចគូទក្របីនោះក៏រីកឡើង ។ ទន្សាយវាចេញមកខាងក្រៅ រួចហើយវាបោលទៅវាស្រែកថា «គ្មានបានគុណប្រយោជន៍អ្វីទេ អញបញ្ឆោតឲ្យតែរួចខ្លួនអញទេ» ។ ទន្សាយវាបោលទៅទៀត ឃើញក្រពើបណ្ដែតខ្លួន ក៏មន្ទិលក្នុងចិត្តថា «នេះជាក្រពើ ឬមួយជាគល់ទេអេះ?» ។ ទន្សាយគិតដូច្នោះហើយ ទើបស្រែកទៅថា «បើជាក្រពើទេ ឲ្យអណ្ដែតបណ្ដោយទឹក បើជាគល់ឲ្យអណ្ដែតច្រាស់ទឹកឡើងទៅវិញ» ។ ឯក្រពើ ឮគេថាដូច្នោះហើយ គិតថា «អញថាធ្វើជាគល់ ឥឡូវគេថា បើគល់ឲ្យអណ្ដែតច្រាសទឹក បើដូច្នេះអញធ្វើជាអណ្ដែតច្រាសទឹកទៅវិញចុះ» គិតហើយក៏ហែលច្រាសទឹកទៅវិញ ។ ទន្សាយឃើញហើយថា យី!មើលន៎! អាក្រពើ អាឯងមកបញ្ឆោតអញ កុំអាបញ្ឆោតមិនបានទេ» ។ ក្រពើឮហើយគិតថា «អញចាញ់ប្រាជ្ញាទន្សាយទៀតហើយ» ទើបគិតទៀតថា «បើដូច្នេះ អញឡើងលើគោក ធ្វើជាងាប់វិញទើបស្រួល» គិតដូច្នោះហើយ ក៏ឡើងទៅដេកលើគោក ហាមាត់ដូចជាងាប់ ។ ឯទន្សាយ ដើរទៅដើរមក ឃើញក្រពើដេកដូច្នោះ គិតថា «អានេះងាប់ហើយតើ» ។ រួចដើរចូលទៅមាត់ក្រពើនោះ ហើយក៏អង្អែលចង្កូមលេងថា «អើចង្កូមធំនេះ ធ្វើដងកាំបិតស្នៀតអញ ចង្កូមតូចនោះធ្វើដងកាំបិតស្លា ឲ្យប្រពន្ធអញវាកាត់គាត» ។ កំពុងតែរៀបរាប់ ក្រពើត្របាក់ឃ្លុប ។ ទន្សាយបោលប្លូចចូលទៅក្នុងពោះ ហើយស្រែកថា «ឱ! ជាណាស់ហើយនេះ អញកំពុងតែចង់ស៊ីពោះវៀនបត់ចន្ទាសផង ឥឡូវបានមកដល់ក្នុងពោះហើយ អញស្រាវពោះវៀនបត់ចន្ទាសអាឯងស៊ីឲ្យអស់» ថាហើយក៏ផ្ទាត់ក្រចកឮប្រេះៗ ។ ឯក្រពើឮហើយភ័យណាស់ អង្វរថា «បងទន្សាយ អាណិតចេញទៅចុះ! ខ្ញុំមិនហ៊ានខាំបងឯងទេ» ។ ទន្សាយថា «អើ! បើអាឯងអង្វរអញ ៗ អាណិត អញលែងអាឯង» ។ ក្រពើហាមាត់ឡើងហើយ ទន្សាយនោះបោលចេញទៅ ។

ទន្សាយបោលទៅ ៗ ឃើញអង្កត់ឈើមួយនៅមាត់ត្រពាំង ឡើងទៅអង្គុយលើដង្កត់ឈើនោះ ។ ដល់ថ្ងៃក្ដៅឡើង ជ័រឈើរលាយជាប់ឯគូទទន្សាយនៅដង្កត់ឈើទៅ ។ ជូនមានកូនដំរីមួយមកផឹកទឹកត្រពាំងនោះ ។ ទន្សាយឃើញហើយថា «យើឯង! ម្ដេចក៏មកផឹកទឹកអញ? ទេវតាលោកឲ្យអញចាំនៅនេះ» ។ កូនដំរីភ័យណាស់ ក៏បោលទៅប្រាប់មេ មេឮកូនប្រាប់ដូច្នោះ ខឹងណាស់មករកទន្សាយសួរថា «អាទន្សាយ ឯងម្ដេចក៏មិនឲ្យកូនអញផឹកទឹក?» ។ ទន្សាយថា «អើអញមិនឲ្យផឹក ត្បិតទេពតាលោកឲ្យអញចាំ» ។ មេដំរីនោះខឹងណាស់បួងកន្ត្រាក់ឯទន្សាយនោះចោលទៅ ។ ទន្សាយអរណាស់ ត្បិតបានរួចខ្លួន ពីជ័រឈើនោះ បោលពីនោះទៅចូលក្នុងចម្ការតាចាស់ម្នាក់ ។ ឯតាចាស់នោះ គាត់ដាំត្រសក់ពេញតែចម្ការ ។ ទន្សាយនោះ លួចត្រសក់គាត់ស៊ីតែសព្វថ្ងៃ ។ តាចាស់ខឹងណាស់ គិតធ្វើអន្ទាក់ដាក់ ។ ដល់យប់មួយនោះ ទន្សាយទៅស៊ី ត្រូវអន្ទាក់តាចាស់ ។ ទន្សាយភ័យណាស់ ក្រែងតាចាស់មកទាន់ ។ ពេលនោះ មានគីង្គក់មួយលោតចុះលោតឡើង ។ ទន្សាយឃើញហើយអរណាស់ ក៏ធ្វើជាសួរថា «អើបងគីង្គក់! បងឯងកើតអ្វី? ។ គីង្គក់ប្រាប់ទៅវិញថា «ខ្ញុំកើតស្រែង» ។ ទន្សាយនិយាយថា «ឱអ្នកបង! បងឯងដោះអន្ទាក់ឲ្យខ្ញុំ ៗ នឹងធានាមើលស្រែងបងឯងឲ្យជា កុំឲ្យបងឯងព្រួយចិត្ត» ។ គីង្គក់ឮទន្សាយថា «មើលស្រែងឲ្យជា» ក៏អរណាស់

ខំដោះអន្ទាក់ ឲ្យទាល់តែរួច ។ ឯទន្សាយបានរួចពីអន្ទាក់ហើយ ក៏និយាយថា «ស្រែងពីជីដូនជីតាអាមក ។ អាណា មើលជា» ។ គីង្គក់ខឹងណាស់ ខំលោតដេញតាមទន្សាយក៏មិនបានទាន់ឡើយ ។

ពីនេះនឹងនិយាយពីតាចាស់ គាត់ភ្ញាក់ឡើងពីព្រឹក រៀបរេចស្លាម្លួចហើយ ក៏ដើរជាប្រញាប់ ទៅរកមើលចម្ការត្រសក់ គាត់ ហើយចូលទៅមើលឃើញស្នាមដែលត្រូវទន្សាយរួចទៅនោះ ។ តាចាស់ស្តាយណាស់ គក់ទ្រូងគក់ស្មាថា « អញខានស្លសាច់ទន្សាយសោះ» ។ គាត់ក៏រៀបដាក់ជាថ្មី ដល់យប់ឯក្រោយទៀត ទន្សាយនឹកភ្នកចង់ស៊ីត្រសក់ ក៏បោលចូលទៅក្នុងចម្ការ ភ្លេចនឹកអំពីអន្ទាក់ ដោយសារឃ្លានចង់ស៊ីត្រសក់ ទៅជាន់លើអន្ទាក់ ជាប់ឯជើង ទន្សាយភ័យណាស់ មិនដឹងគិតធ្វើដូចម្តេច នឹងបានរួចពីអន្ទាក់ ។ ឯសត្វគីង្គក់ ឃើញទន្សាយជាប់អន្ទាក់ ក៏អរណាស់ លោតឡើងទះដៃផ្តន្ទាថា «ឯងធ្លាប់តែបញ្ឆោតអញ ឥឡូវនេះមកជាប់អន្ទាក់ក្រញោនធ្វើមុខភ្លឹះៗ ដូចជាមុខខ្មោច នរណានឹងជួយឯងទៀត» ។ ឯទន្សាយ ឮគីង្គក់ផ្ចាន់ផ្ចាន់ផ្ចាញ់ផ្ចល់ នឹកខឹងក្នុងចិត្តណាស់ ប៉ុន្តែ ជាសត្វមានប្រាជ្ញា ធ្វើជាមិនខឹង និយាយលួងលោមគីង្គក់ថា «ពីមុនខ្ញុំបញ្ឆោតបងឯង ពីព្រោះខ្ញុំទាល់ចំណេះ មិនចេះថ្នាំមើលស្រែងបងឯងម្តងនេះ ខ្ញុំនិយាយប្រាកដប្រជាមែនទែន ត្បិតខ្ញុំឃើញកូនក្រមុំគេល្អណាស់មុខកំប្លង់ៗ ថ្ពាល់បំផូរដូចផ្កាកុលាប ខ្ញុំនឹងទៅដណ្តឹងឲ្យបងឯងៗ កុំព្រួយចិត្ត ត្បិតខ្ញុំបាននិយាយម្តងរួចហើយ គេថានឹងឲ្យជាប្រពន្ធបងឯង ។ បងឯងជួយដោះខ្ញុំឲ្យរួចចេញពីអន្ទាក់ម្តងនេះ ខ្ញុំទៅដណ្តឹងឲ្យ កុំព្រួយចិត្ត» ។ គីង្គក់ ហេតុតែជាសត្វឆ្កួតនឹងស្រី បានឮទន្សាយនិយាយពីកូនក្រមុំគេដូច្នោះ អរណាស់អត់មិនបាន ញញឹមញញែមកន្ទេះកន្ទោញ២ចង់បានកូនក្រមុំគេ ហើយនិយាយថា «បងទន្សាយឯងនិយាយឲ្យមែនទែន កុំបញ្ឆោតខ្ញុំដូចពីមុនទៀត» ។ ទន្សាយឆ្លើយថា «ទេ! បញ្ឆោតអីច្រើនដងម្ល៉េះ ពីមុនវាទាល់ចំណេះខ្ញុំទេ បានជាខ្ញុំកុហក ម្តងនេះងាយទេ ត្បិតនៅស្រុកអង្គរមានកូនក្រមុំច្រើនណាស់ ទោះបីខ្ញុំមិនទៅ បងឯងទៅដណ្តឹងខ្លួនឯងក៏គេឲ្យដែរ ត្បិតឥឡូវក្រមុំថោកណាស់ ក្រមុំដប់មួយស្លឹង៣ (បានជាមានពាក្យគេច្រៀងជាប់ដល់សព្វថ្ងៃថា «ក្រមុំដប់មួយស្លឹង» ដោយសារឃើញគីង្គក់ហែលទឹកទៅយកប្រពន្ធស្រុកអង្គរ) ។ គីង្គក់ ក៏ដោះអន្ទាក់ឲ្យទន្សាយទៀត ។ ទន្សាយបានរួចពីអន្ទាក់ហើយ ក៏ស្ទុះលោតផ្លោតបោលទៅ ហើយថា «គីង្គក់ឯង ស្រែងគគ្រាតណាស់ នរណាគេនឹងឲ្យកូនក្រមុំគេ អញបញ្ឆោតឯងទេ » ។ ឯគីង្គក់ ឮទន្សាយថាដូច្នោះ ខឹងណាស់ ចង់តែបោកខ្លួនឲ្យស្លាប់នឹងភ្លឺស្រែ ប៉ុន្តែ មកគិតមានៈក្នុងចិត្តចង់បានកូនក្រមុំស្រុកអង្គរហើយក៏ទៅសួរ ជួបបឹងសត្វកំពូលអាចម៍ ៗ សួរថា «បងគីង្គក់ទៅណា?» ។ គីង្គក់ប្រាប់ថា «ខ្ញុំទៅរកប្រពន្ធស្រុកអង្គរ» ។ សត្វកំពូលអាចម៍ថា «បងឯងទៅដល់ឬ? ថ្មើរនេះទៅហើយ! ។ គីង្គក់នោះ ហេតុតែចង់បានប្រពន្ធពេក ក៏ប្រាប់ទៅកំពូលអាចម៍ថា «ខ្ញុំទៅហើយ ខ្ញុំត្រឡប់មកស៊ីបាយព្រឹកវិញ ។ គីង្គក់ឃើញកំពូលអាចម៍ធ្វើងួងៗ ក៏សួរថា «បងឯងធ្វើអ្វី?» ។ កំពូលអាចម៍ប្រាប់ថា «ខ្ញុំក្រឡឹងដុំរទេះ» ។ គីង្គក់សួរថា «ឯងធ្វើដុំរទេះអ្វីខ្លីដល់ម្ល៉េះ ? ។ កំពូលអាចម៍ឆ្លើយថា «មិនខ្លីទេ ខ្ញុំគិតនឹងកាត់ឲ្យបានជាពីរកំណាត់ផង ឲ្យគ្រប់មួយសម្រាប់តែម្តង» ។ (បានជាកំពូលអាចម៍ថាដូច្នេះនេះ ឲ្យទាន់ប្រាជ្ញាដែលគីង្គក់និយាយជំហរថា «ត្រឡប់មកស៊ីបាយព្រឹកវិញ») ។ គីង្គក់ ក៏ហែលទឹកពីស្រុកទន្លេធំ គិតទៅយកប្រពន្ធពីស្រុកអង្គរ បើជួបនឹងសត្វឯណាគេសួរ សុទ្ធតែប្រាប់គេថា «ទៅយកប្រពន្ធឯស្រុកអង្គរ» លុះជួបនឹងត្រីទីពោ វាក៏ត្របាក់ស៊ីលេបទៅ ។ តអំពីនេះ នឹងនិយាយអំពីទន្សាយ កាលរួចពីអន្ទាក់តាចាស់នោះហើយ ក៏បោលទៅពួននឹងគុម្ពរពាក់មួយ ។ ពេលនោះ មានខ្លាមួយ មកឃើញទន្សាយពួននៅគុម្ពរពាក់នោះ វាក៏លបមកចង់ខាំទន្សាយស៊ី ។ ឯទន្សាយ ដឹងថាខ្លាលបចង់ខាំស៊ីខ្លួនហើយ ធ្វើជាគ្រហែមថា «អ៊ើម! អញស៊ីដំរីប្រាំមិនស្កាំផ្ទៃ ស៊ីគ្រប់ខារប៉ុន

មេដៃ ស្អាបំពង់កទល់ល្វាច ធ្វើម្ដេចបានថ្លើមខ្លាមកស៊ី សោះវាស្អាបំពង់ក» ។ ខ្លាឮទន្សាយថាដូច្នោះ ក៏គិតខ្លាចមិនហ៊ានខាំ ហើយទៅរកបបួលស្វា លុះទៅជួបនឹងស្វាហើយ និយាយប្រាប់ស្វាថា «អាដែងសត្វអីតូចមួយ វាថាស៊ីដំរីប្រាំមិនស្កាំផ្ទៃ ស៊ីគ្រប់ខារប៉ុនមេដៃ ស្អា-កទល់ល្ងាច ធ្វើម្ដេចនឹងបានថ្លើមខ្លាស៊ី កុំឲ្យស្អាក, ខ្ញុំឮដូច្នោះហើយ ខ្ញុំភ័យខ្លាចណាស់» ។ ស្វាឮខ្លានិយាយប្រាប់ដូច្នោះហើយ ក៏សួរទៅវិញថា «សត្វនោះប៉ុនណា រូបវាដូចម្ដេច?» ។ ខ្លាប្រាប់ទៅស្វាថា «សត្វនោះតូចប៉ុនកដៃខ្ញុំ ហើយមានស្លឹកត្រចៀកវែង កន្ទុយខ្លី» ។ ស្វាឆ្លើយថា «ឱ!នេះ គេហៅសត្វទន្សាយ អានេះវាជំហរណាស់ បងឯងកុំខ្លាចវា» ។ ឯខ្លាឮស្វាថាដូច្នោះហើយថា «ទេ! បងស្វា ខ្ញុំឃើញកម្ទេចភ្លុកដែលវាស៊ីដំរីសល់នៅនោះ មានពាសពេញប្របខ្លួនវា» ។ ឯស្វាថា «ទេ មិនមែនទេ! បងខ្លាឯងទៅនឹងខ្ញុំៗ ជូនបងឯងទៅមើលឲ្យច្បាស់មែនទែន» ។ ខ្លាប្រកែកថា «ទេខ្ញុំខ្លាចវាណាស់ វាថាចង់ស៊ីថ្លើមខ្ញុំ បើបងឯងជូនខ្ញុំទៅ បើវាដេញខាំខ្ញុំ ហើយបងឯងរត់ឡើងដើមឈើបាត់ទៅ វានឹងខាំខ្ញុំយកទៅស៊ីតតអំពើ» ។ ស្វាថា «ឱ! បងឯងឆោតអីដល់ម្ល៉េះ! បើបងឯងមិនជឿខ្ញុំ បងឯងយកវល្លិមកចងចង្កេះខ្ញុំ ភ្ជាប់នឹងបងឯង ឲ្យជាប់ទាំងពីរនាក់ហើយសឹមទៅ» ។ ខ្លាឮស្វាថាដូច្នោះ ក៏បោចវល្លិមកចងចង្កេះទាំងពីរនាក់ជាប់ ហើយបបួលគ្នាដើរទៅ។ ឯទន្សាយកាលដែលខ្លាទៅវិញ ក៏ទៅអង្គុយលើដំបូក ១ ប្របទីនោះ ។ លុះទន្សាយក្រឡេកមើលទៅឃើញខ្លានិងស្វាចងចង្កេះជាប់គ្នា ហើយដើរចូលមកដូច្នោះ ក៏អើតឡើងគ្រហែមថា «អ៊ែម ៗ! អាស្វាក្រញ៉ាំ ជំពាក់បំណុលអញ ២-៣ ឆ្នាំយកឯអាខ្លាកញ្ចាស់សំគមមកឲ្យអញ» ។ ខ្លាឮទន្សាយថា «ស្វាយកខ្លួនមកផាត់បំណុលឲ្យវាដូច្នោះ ក៏ភ័យណាស់ ស្ទុះបោលដូចគេកន្ទ្រាក់ស្វាដួលផ្កាប់ផ្ងារហាមាត់ នឹងស្ដីក៏មិនរួច ខ្លាប្រឹងតែបោលដូចជាគេបោកស្វាទៅលើដង្គត់ឈើស្លាប់មាត់ស្ញេញ ហើយខ្លាបោលទៅឆ្ងាយ បែរមើលមកក្រោយឃើញមាត់ស្វាស្ញេញដូច្នោះ គិតស្មានថាជាស្វាសើច ក៏ខំប្រឹងកន្ទ្រាក់ ទាញផ្ដាច់ខ្សែចំណងចេញពីរចង្កេះ ហើយបោលតែម្នាក់ឯងទៅ ។ ឯទន្សាយ លុះដល់ព្រលប់យប់ងងឹត គិតចង់ស៊ីស្រូវសំណាបល្បាស់ខ្ចី ហើយទៅជិតស្រុកគេ ឃើញសំណាបលាស់ខៀវខ្ចី ក៏ស្ទុះលោតចូលទៅស៊ីស្រូវសំណាបឆ្អែតហើយចូលទៅពួនក្នុងព្រៃវិញ ។ ព្រឹកឡើងម្ចាស់សំណាបមកមើល ឃើញស្នាមទន្សាយស៊ីសំណាបខូចអស់ ម្ចាស់សំណាបនោះ ។ លុះយប់ ទន្សាយចេញមករកស៊ីសំណាបទៀត ក៏ត្រូវអន្ទាក់ដែលដាក់នោះ ។ ទន្សាយ ជាប់អន្ទាក់ហើយ ភ័យណាស់ មិនដឹងគិតទៅអង្វរអ្នកឯណាឲ្យមកជួយដោះ ហើយគិតធ្វើពុតជាងាប់រឹងស្ដូក ។ លុះព្រឹកឡើងម្ចាស់អន្ទាក់ ភ្ញាក់ពីព្រលឹម ក្រោកជាប្រញាប់ រៀបខ្លួនប្រាណដើរទៅមើលអន្ទាក់ ឃើញទន្សាយ ជាប់អន្ទាក់ងាប់រឹងស្ដូក ។ ម្ចាស់អន្ទាក់អរណាស់ ចូលទៅដោះទន្សាយនោះ ហើយរៀបដាក់អន្ទាក់នោះទៅវិញ ។ ទន្សាយដឹងថាគេដាក់ខ្លួននៅដីហើយ ក៏ស្ទុះចូលទៅព្រៃបាត់ទៅ ។ ម្ចាស់អន្ទាក់ មើលទៅឃើញទន្សាយបោលចូលទៅក្នុងព្រៃ ទើបភ្ញាក់ខ្លួន ហើយក្រោកឡើងគក់ទ្រូងថា «ឱអាចោរទន្សាយពុតខូច រស់ទេតើ! អញស្មានថាវាងាប់ ឥឡូវវាបោលទៅក្នុងព្រៃព្រងើយ អើ! អត់ឲ្យម្ដង ថ្ងៃក្រោយគង់តែវាភ្លេចត្រចៀក មកត្រូវអន្ទាក់អញទៀតមិនខានទេ» ។ លុះពីរបីថ្ងៃក្រោយមកទន្សាយនឹកចង់ ស៊ីស្រូវសំណាបទៀត ហើយបោលចូលទៅក្នុងស្រែ ភ្លេចគិតពីអន្ទាក់នោះ អាល័យតែនឹកចង់ស៊ីសំណាប ក៏ទៅជាប់អន្ទាក់នោះទៀត ។ ទន្សាយលុះជាប់អន្ទាក់ហើយ ភិតភ័យណាស់ មិនដឹងបើនឹងគិតធ្វើម្ដេចឲ្យរួច ទាល់ប្រាជ្ញធ្វើមុខស្រមេះ ។ លុះព្រឹកឡើង ម្ចាស់អន្ទាក់ មកឃើញទន្សាយជាប់អន្ទាក់ អរណាស់ស្ទុះម្នីម្នា ចូលទៅដោះទន្សាយចេញពីអន្ទាក់ ហើយថា «ឯងធ្លាប់តែមានពុតធ្វើជាងាប់ ម្ដងនេះ ឯងធ្វើម្ដេចក៏អញមិនលែងអាឯងទៀតដែរ, អញទុកឯងគ្រាន់តែនឹងមើលមុខ ត្បិតឯងមានពុតចេះធ្វើងាប់» ហើយយកទន្សាយទៅផ្ទះ ។ លុះដល់ផ្ទះ

ហើយ ក៏យកអង្រុតក្រុងទន្សាយចាប់ ។ ជួនជាព្រឹកនោះ អ្នកនោះបានត្រីរស់មួយផង យកមកប្រោះទុកក្នុងថ្លាងដាក់ប្របគ្នានឹងទន្សាយ ហើយនឹកក្នុកឡើងថា «លោកសង្ឃនៅវត្ត នេះចាប់យាមពូកែ ទាយឆុតណាស់, បើដូច្នោះ អញនឹងទៅល្បងឲ្យលោកចាប់យាមមើល ជាឆុតមែនឬដូចម្ដេច?» ហើយអ្នកនោះផ្ដាំប្រពន្ធថា «ឯងមើលទន្សាយនិងត្រីផង ក្រែងវារួច» ហើយដើរចូលទៅក្នុងវត្ត ឡើងទៅលើកុដិ ក្រាបថ្វាយបង្គំលោក ពិតពុទ្ធដីកាថា «ខ្ញុំព្រះករុណា ឮល្បីថាលោកគ្រូចេះចាប់យាមឆុតណាស់» ។ ឯលោកមានពុទ្ធដីកាថា «ចេះមែន ប៉ុន្តែឆុត មិនឆុតមិនហ៊ានអួតទេ» ។ អ្នកនោះឆ្លើយឡើងថា «សូមមេត្តាប្រោសទាយឲ្យខ្ញុំករុណាបន្តិច ក្នុងវេលាព្រឹកនេះឯង តើខ្ញុំព្រះករុណានឹងមានលាភអ្វីទទួលបាន?» ។ លោកនោះឆ្លើយឡើងថា «ទេ! អាចក្ដីមិនហ៊ានទាយទេ! ។ អ្នកនោះថា «សូមមេត្តាប្រោស ទាយឲ្យទានបន្តិច, ខ្ញុំករុណាចង់ដឹងថានឹងបានអ្វីទទួលទានក្នុងវេលាព្រឹកនេះ» ។ លោកសង្គ្រាជឆ្លើយឡើងថា «ទេ! ក្រែងញោមអន់ចិត្ត» ។ អ្នកនោះគិតក្នុងចិត្តថា «បើលោកនេះទាយត្រូវ អញឲ្យសាច់ទន្សាយនិងត្រីរស់ឆាន់, បើលោកទាយមិនត្រូវទេ អញមិនឲ្យឆាន់សោះ, អញស៊ីតែពីរនាក់នឹងប្រពន្ធអញ «នឹកតែក្នុងចិត្តហើយពិតពុទ្ធដីកាលោកថា ទេ! ខ្ញុំករុណាមិនអន់ចិត្តទេ» ។ លោកក៏យកតម្រាមកមើល ហើយទាយថា «ញោមគ្មានលាភអ្វីទេ!» ។ អ្នកនោះលាលោកត្រឡប់មកផ្ទះវិញ ហើយនឹកថា «លោកនេះចាប់យាមមិនឆុតទេ អញគិតស្មានក្រែងលោកទាយត្រូវនឹងប្រគេនសម្លលោកឆាន់, ឥឡូវនេះ លោកទាយមិនត្រូវ ដូច្នេះអញស៊ីតែពីរនាក់នឹងប្រពន្ធអញ» គិតដូច្នេះហើយដើរមកដល់ផ្ទះ បង្គាប់ប្រពន្ធឲ្យដណ្ដាំបាយ ។

ឯទន្សាយនឹងត្រីរស់គិតគ្នាថា បងត្រីឯងធ្វើជាងាប់ផ្ការពោះ បើគេមកចាប់ បងឯងទៅកាប់ស្លសុី ហើយគេដាក់បងឯងនៅប្របទឹក បងឯងលោតចុះហែលបន្តិចទៅ រួចធ្វើជាផ្ការពោះទៀត ឲ្យគេយកអង្រុត ដែលគេគ្របខ្ញុំទៅរុតចាប់បងឯង បងឯងឃើញគេយកអង្រុតទៅ សឹមបងឯងស្ទុះហែលឲ្យបាត់ទៅ ។ ឯជនទាំងពីរនាក់ប្ដីប្រពន្ធ លុះប្រពន្ធដណ្ដាំបាយឆ្អិនហើយ ប្ដីយកត្រីទៅស្រកានៅប្របមាត់ត្រពាំង នៅមុខផ្ទះ ។ ត្រីធ្វើជាងាប់ផ្ការពោះរឹងស្ដូកមិនកម្រើកខ្លួនសោះ ។ បុរសនោះគិតស្មានថាជាងាប់ ចាប់យកត្រីទៅដាក់ប្របមាត់ទឹក ត្រីក៏ស្ទុះប្លោតលោតចុះទៅក្នុងទឹក ធ្វើតាមពាក្យទន្សាយផ្ដាំសព្វគ្រប់ ។ ឯបុរសនោះ លុះឃើញត្រីលោតចូលទៅក្នុងទឹកហែលផែលៗដូច្នោះ ក៏លោតទៅចាប់ ។ ត្រីស្ទុះទៅទៀត ហើយធ្វើជាផ្ការពោះ ផែលៗ ដូច្នេះពីរបីដង អ្នកនោះចាប់មិនបាន ស្រែកហៅប្រពន្ធឲ្យយកអង្រុតទៅជាប្រញាប់ ។ ប្រពន្ធ មិនបានជាគិតដល់ទន្សាយ ក៏ស្ទុះកញ្ឆក់យកអង្រុតទៅឲ្យប្ដីរុតត្រីក្នុងត្រពាំង ទាំងពីរនាក់ប្ដីនឹងប្រពន្ធទទឹកសំពត់អាវអស់ ។ ត្រីឃើញអង្រុតក៏ស្ទុះហែលទៅក្នុងទឹកជ្រៅបាត់ទៅ ។ បុរសប្ដីប្រពន្ធ ខឹងណាស់ ខំរុតរកត្រីពុំឃើញសោះ រងាណាស់ទ្រាំមិនបាន ពីព្រោះត្រូវរដូវខ្យល់ពីឯជើង ហើយព្រឹកព្រហាមផង ញ័រទាំងដៃជើងរណ្ដំទាំងធ្មេញ ។ ទាំងពីរនាក់ប្ដីប្រពន្ធ រត់ឡើងមកអាំងភ្លើងជើងក្រាន ដែលដណ្ដាំបាយនោះ អង្គុយច្រហោងទាំងពីរនាក់ទល់មុខគ្នា ក៏នឹកឃើញទំនាយដែលលោកសង្គ្រាជចាប់យាមថា «គ្មានលាភអ្វីទេ» ត្រូវតាមលោកចាប់យាមឲ្យនោះមែន ។ អ្នកនោះ ក៏ជឿលោកគ្រូនោះថា «ចាប់យាម ឆុតពូកែមែន» ។

**ត្រីរស់ក៏រួច ទន្សាយក៏រួច**